ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ៖ ០៤០/២១ ស.ល.

**សូមគោរពជូន**
**ឯកឧត្តម ស៊ិន ចាន់ថុល ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**កម្មវត្ថុ៖** សំណើសុំចាត់សមាសភាព រដ្ឋលេខាធិការ ០១រូប តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីចូលជាសមាជិកបន្ថែមរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)។

**យោង៖** - លិខិតលេខ ០២៥/២១ សណ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

- ចំណារដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១។

តបតាមកម្មវត្ថុ និងយោងខាងលើ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មានកិត្តិយសសូមជម្រាបជូន **ឯកឧត្តមទេសរដ្ឋមន្ត្រី** មេត្តាជ្រាបថា វិស័យដឹកជញ្ជូនបានរួមចំណែកយ៉ាងសំខាន់ក្នុងដំណើរការអភិវឌ្ឍជាតិ ហើយមធ្យោបាយធ្វើដំណើរគ្រប់ប្រភេទ ក៏បានជួយសម្រួលការរស់នៅក្នុងជីវភាពប្រចាំថ្ងៃរបស់មន្ត្រីរាជការ អាជីវករ និងប្រជាពលរដ្ឋ គ្រប់លំដាប់ថ្នាក់។ ទន្ទឹមនឹងនេះ មធ្យោបាយធ្វើដំណើរក៏ត្រូវបានប្រើប្រាស់ក្នុងការចល័តពលករពីកន្លែងមួយទៅកន្លែងមួយទៀត ឬការជួញដូរមនុស្សពីតំបន់មួយទៅតំបន់មួយទៀតផងដែរ។

ដោយមើលឃើញពីសារៈសំខាន់នៃវិស័យដឹកជញ្ជូន ក្នុងការចូលរួមអនុវត្តយុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅប្រទេសកម្ពុជា អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សូមស្នើ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ដើម្បី៖

- ចាត់សមាសភាព រដ្ឋលេខាធិការ ០១រូប តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីចូលរួមជាសមាជិកបន្ថែមក្នុងក្រុមការងារបង្ការទប់ស្កាត់ ក្រុមការងារការពារជនរងគ្រោះ ក្រុមការងារទេសន្តរប្រវេសន៍ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន** មេត្តាពិនិត្យ និងសម្រេចដោយអនុគ្រោះ។

សូម **ឯកឧត្តមទេសរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីនាងខ្ញុំ។

ថ្ងៃ សុក្រ [?] ៨កើត [?] ខែ មាឃ [?] ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៩ [?] ខែ កុ.ម [?] ឆ្នាំ ២០២១

**ជ. ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**
**អនុប្រធានអចិន្ត្រៃយ៍**

ជូ_ប៊ុនអេង

**សូមជូនភ្ជាប់នូវ៖**
**ឯកសារពាក់ព័ន្ធចំនួន ០៥ច្បាប់។**